# របាំត្រឡោក

កម្ពុជា សម្បូណ៌ទៅដោយដើមដូង ដែលជាផ្នែកមួយនៃធនធានកសិកម្មរបស់ប្រទេស។ ដើមនិងផ្លែដូង មានសារៈសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនកសិករខ្មែរ ហើយក៏ជាលក្ខណៈពិសេសមួយរបស់ភូមិខ្មែរផងដែរ។ បើមើលពីចម្ងាយទៅ គេឃើញដើមដូងដុះខ្ពស់ផុត លើសពីដើមឈើឯទៀតៗនៅក្នុងភូមិ ដែលហាក់ដូចជាផ្ដល់ភាពស្ងប់ស្ងាត់សុខដុមរមនា ដល់ភូមិស្ថាននិងប្រជាជន ក៏ដូចជាជម្រកនៃជីវិតមនុស្សនិងសត្វទៀតផង។

នៅពេលមានបុណ្យទានផ្សេងៗ គេយកធាងនិងស្លឹកដូងមកកាត់ធ្វើទៅជាគ្រឿងតុបតែងលម្អដើម្បីញ៉ាំងពិធីបុណ្យឱ្យមានសម្ផស្សស្រស់ស្រាយរីករាយអធឹកអធម។ ខ្មែរយើងតែងតែនិយាយថា ដើមដូងជានិមិត្តរូបនៃភាពស្វាគមន៍។ អ្នកធ្វើដំណើរឆ្ងាយពីភូមិមួយទៅភូមិមួយ នឿយហត់អស់កម្លាំង ជួនកាលគេក៏ឈប់សម្រាកនៅក្រោមដើមដូងមុននឹងបន្តដំណើររបស់គេទៅមុខទៀត។ ដោយអស់កម្លាំងផង ប្រសិនបើគេបានទទួលទានទឹកដូងមួយក្អឹកឬពីរ គេនឹងមានកម្លាំងនិងថាមពលក្នុងការធ្វើដំណើរទៅទៀត។

ក្រោយពីផ្លែដូងដែលនៅលើដើមទុំហើយ វានឹងជ្រុះមកដី។ គេរើសប្រមូលផ្លែទាំងនោះយកមកធ្វើម្ហូបនិងបង្អែមដែលគេចូលចិត្ត។ គេយកលលាដ៍ដូងដែលគេយកទឹកនិងសាច់ចេញអស់ហើយមកធ្វើជាគ្រឿងតុបតែងលម្អគេហដ្ឋានរបស់គេ។ សិល្បករ ដែលផ្ដិតគំនិតពីធម្មជាតិ ច្នៃត្រឡោកដូងឱ្យទៅជាឧបករណ៍សម្រាប់ល្បែងប្រជាប្រិយនិងប្រពៃណីផ្សេងៗ។ អ្នកស្រុកនៅខេត្តស្វាយរៀង លេងល្បែងប្រជាប្រិយមួយមានឈ្មោះថា «ល្បែងគោះត្រឡោក» ដែលគេធ្លាប់សម្ដែងនៅក្នុងឱកាសផ្សេងៗ តែជារឿយៗនៅក្នុងពិធីអាពាហ៍ពិពាហ៍ ដូចជាពិធីភ្ជាប់ពាក្យនិងហែកូនកំលោះពីគេហដ្ឋានខាងប្រុសទៅខាងស្រី។ សៀវភៅ«ល្បែងប្រជាប្រិយខ្មែរ» អះអាងថា ល្បែងគោះត្រឡោកកាលពីសម័យដើមលេងដោយអ្នកលេង

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

*តែម្នាក់ប៉ុណ្ណោះ។[១] ដោយឡែក សិល្បករសិល្បការិនីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក៏បានយកត្រុឡោកដូងមកច្នៃនិងបង្កើតទៅជារបាំត្រុឡោក ឬ របាំគោះត្រុឡោកដែលមានសម្ដែងរហូតមកដល់សព្វថ្ងៃនេះ។ របាំត្រុឡោកបច្ចុប្បន្ន មានអ្នករាំស្រីនិងប្រុសរាំជាគូ។ ប្រហែលជាដោយសារ ល្បែងគោះត្រុឡោកពីដើមត្រូវបានគេប្រើនៅក្នុងពិធីអាពាហ៍ពិពាហ៍ ទើបរបាំនេះចាប់ផ្ដើមដោយបទភ្លេងអាពាហ៍ពិពាហ៍មួយហៅថា «សំពោង» ហើយបន្តភ្ជាប់និងបញ្ចប់ដោយចម្រៀងគោះត្រុឡោក។ ពាក្យពេចន៍នៃចម្រៀងក្នុងរបាំត្រុឡោកបង្កប់នូវអត្ថន័យខ្លឹមសារអប់រំ លាតត្រដាងអំពីជីវិត ធម្មជាតិ និងមនោសញ្ចេតនារបស់ប្រជាកសិករខ្មែរ។*



*[១] ចាប ពិន ១៩៦៤: ៤៧-៤៩*

*អត្ថបទដោយ៖ បណ្ឌិត សំ សំអាង*





## ឯកសារពិគ្រោះ

ចាប ពិន.

១៩៦៤. ល្បែងប្រជាប្រិយខ្មែរ. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang. (1998). *Khmer Folk Dance* (2nd ed.). Washington, DC: Cambodian Network Council.

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង